ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ០១៦៨ ......អ.ប.ស.ឱ.អ.ប.ស

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៩

# សេចក្តីប្រកាសព័ត៌មាន

ក្រសួងសុខាភិបាល មានកិត្តិយសសូមជំរាបជូនអស់លោក-លោកស្រី ជាវេជ្ជបណ្ឌិត និងឱសថការីទាំងអស់ដែលទទួលខុសត្រូវ គ្រឹះស្ថានអាហារ័ណ-នីហារ័ណឱសថ,ឱសថស្ថាន-ឱសថស្ថានរង និងប្រជាពលរដ្ឋទាំងអស់ឱ្យបានជ្រាបថា :

-យោងសេចក្តីប្រកាសព័ត៌មានរបស់អង្គការសុខភាពពិភពលោកលេខ ១១៣ ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការផ្អាកចរាចរនៅលើទីផ្សារ និងនាំចូលនូវប្រភេទឱសថលេប Nimesulide ដែលគេបានរកឃើញនៅក្នុងប្រទេសអៀរឡង់ (Ireland) ថា ការប្រើឱសថនេះបណ្តាលឱ្យមានគ្រោះថ្នាក់ និងប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើថ្លើម ។

អាស្រ័យហេតុនេះ ក្រសួងសូមមានវិធានការដូចតទៅ :

១-គ្រឹះស្ថាននាំចូលឱសថក្នុងស្រុក ដែលធ្វើប្រតិបត្តិការនាំចូល ឬចែកចាយឱសថខាងលើត្រូវចាត់តាំងការប្រមូលឱសថខាងលើពីឱសថស្ថាន-ឱសថស្ថានរងនានា ក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីកំទេចចោល ។ ក្នុងករណីកំទេចចោល ត្រូវមានវត្តមានរបស់ភ្នាក់ងារត្រួតពិនិត្យឱសថ ។

២-គ្រឹះស្ថានលក់ឱសថទាំងអស់ត្រូវបញ្ឈប់ការតាំងលក់ឱសថខាងលើ ចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹងនេះតទៅ ។

៣-គ្រប់មន្ទីរសុខាភិបាលខេត្ត-ក្រុង ត្រូវមានវិធានការ ធ្វើការណែនាំដល់គ្រប់សាខាគ្រឹះស្ថាននាំចូលឱសថ-ឱសថស្ថាន-ឱសថស្ថានរង ធ្វើការប្រមូលឱសថខាងលើមកកំទេចចោល ដោយមានការចូលរួមពីភ្នាក់ងារត្រួតពិនិត្យឱសថ ។

៤-មន្ត្រីភ្នាក់ងារត្រួតពិនិត្យឱសថ នៃក្រសួងសុខាភិបាលត្រូវទទួលភារកិច្ចអនុវត្តសេចក្តីប្រកាសព័ត៌មាននេះឱ្យមានប្រសិទ្ធិភាព។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ឱសថការី ជូ-យិនស៊ីម

**ចំលងជូន**

-ក្រសួងព័ត៌មាន ដើម្បីជួយផ្សាយ

-សមាគមឱសថការីកម្ពុជា ដើម្បីជួយផ្សាយ

-គណៈគ្រូពេទ្យកម្ពុជា ដើម្បីជួយផ្សាយ

គ្រប់មន្ទីរសុខាភិបាលខេត្ត-ក្រុង

-នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង

-គ្រប់ស្ថានីយវិទ្យុ-ទូរទស្សន៍

-គ្រប់សារព័ត៌មាន

-គ្រប់គ្រឹះស្ថានអាហារ័ណ នីហារ័ណឱសថដែលពាក់ព័ន្ធ ដើម្បីអនុវត្ត

-គ្រប់ឱសថស្ថាន-ឱសថស្ថានរង ដើម្បីអនុវត្ត

-ឯកសារ

552